**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

លេខ ៖ ០០១/៥៥ សណន

# សេចក្តីណែនាំ

## ស្តីពី

## ការជំរុញការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ទាំងដូសមូលដ្ឋាន និងទាំងដូសជំរុញ ព្រមទាំងការពង្រឹងការអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាល ដើម្បីប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសមេរោគបំប្លែងខ្លួនថ្មី ប្រភេទអូមីក្រុង ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

អនុលោមតាមសារាចរលេខ **០១ សរ** ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពី ការជំរុញការចាក់វ៉ាក់សាំងកូវីដ-១៩ និងការពង្រឹងការអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាល ដើម្បីប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសមេរោគបំប្លែងខ្លួនថ្មី ប្រភេទអូមីក្រុង ស្របពេលនៃការបើកដំណើរការសេដ្ឋកិច្ច-សង្គមឡើងវិញលើគ្រប់វិស័យ តាមគន្លងប្រក្រតីភាពថ្មី **រដ្ឋបាលរាជធានីភ្នំពេញ** សូមធ្វើការណែនាំដល់បណ្តាអង្គភាពរដ្ឋក្រោមឱវាទរដ្ឋបាលរាជធានីភ្នំពេញ វិស័យឯកជន និងប្រជាពលរដ្ឋទាំងអស់ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ត្រូវជំរុញការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ទាំងដូសមូលដ្ឋាន និងទាំងដូសជំរុញ ព្រមទាំងពង្រឹងការអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាល ដូចខាងក្រោម៖

១. អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌទាំង១៤ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ គ្រប់មន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ និងវិស័យឯកជនទាំងអស់ ត្រូវសហការរួមគ្នា បង្កើនការយកចិត្តទុកដាក់ក្នុងការអប់រំ ផ្សព្វផ្សាយ និងក្រើនរំលឹកឱ្យបានទូលំទូលាយបន្ថែមទៀត ជូនដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ លោកគ្រូ-អ្នកគ្រូ បុគ្គលិក កម្មករ-និយោជិត ក្រុមសេដ្ឋកិច្ចក្រៅប្រព័ន្ធ សិស្ស-និស្សិត ប្រជាពលរដ្ឋទូទៅ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ អំពីភាពចាំបាច់នៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដោយត្រូវរៀបចំយន្តការជាក់លាក់ និងបង្កលក្ខណៈងាយស្រួល ដើម្បីបង្កើនល្បឿននៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ទាំងដូសមូលដ្ឋាន និងទាំងដូសជំរុញ (ដូសទី៣ សម្រាប់ប្រជាពលរដ្ឋ និងដូសទី៤ សម្រាប់មន្ត្រីជួរមុខ) ស្របតាមគម្លាតរយៈពេលកំណត់របស់ក្រសួងសុខាភិបាល ឱ្យសម្រេចបានឆាប់រហ័ស ដើម្បីធានាឱ្យបាននូវភាពស៊ាំសហគមន៍រឹងមាំពិតប្រាកដមួយ សំដៅទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការឆ្លងរាលដាលនៃមេរោគបំប្លែងខ្លួនថ្មី ប្រភេទអូមីក្រុង។

២. មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ លោកគ្រូ-អ្នកគ្រូ បុគ្គលិក កម្មករ-និយោជិត ក្រុមសេដ្ឋកិច្ចក្រៅប្រព័ន្ធ សិស្ស-និស្សិត និងប្រជាពលរដ្ឋទាំងអស់ ត្រូវរួសរាន់អញ្ជើញទៅចាក់វ៉ាក់សាំង ឬ នាំយកបុត្រធីតារបស់លោកអ្នកដែលមានអាយុចាប់ពី **៥ ឆ្នាំឡើងទៅ** ឱ្យទៅទទួលវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ទាំងដូសមូលដ្ឋាន និងទាំងដូសជំរុញ (ដូសទី៣ សម្រាប់ប្រជាពលរដ្ឋទូទៅ និងដូសទី៤ សម្រាប់មន្ត្រីជួរមុខ) នៅតាមមន្ទីរពេទ្យរដ្ឋ និងមណ្ឌលសុខភាពទាំង **៤២ ទីតាំង** និងទីតាំងសមស្របមួយចំនួនទៀត ដែលបានរៀបចំជូនក្នុងរាជធានីភ្នំពេញ។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

៣. គ្រប់បណ្តាអង្គភាពរដ្ឋក្រោមឱវាទរដ្ឋបាលរាជធានីភ្នំពេញ គ្រឹះស្ថានសិក្សា រោងចក្រ-សហគ្រាស និងអាជីវកម្មដ្ឋានទាំងអស់ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ត្រូវស្រង់ស្ថិតិ និងធ្វើបច្ចុប្បន្នភាពជាប់ជាប្រចាំអំពីចំនួនអ្នកដែលបានចាក់វ៉ាក់សាំងដូសមូលដ្ឋាន និងដូសជំរុញ ក្នុងអង្គភាព ឬ ទីតាំងអាជីវកម្មរបស់ខ្លួន និងត្រូវជំរុញអ្នកក្រោមបង្គាប់ឱ្យទៅទទួលវ៉ាក់សាំងបានទាន់ពេលវេលា ស្របតាមគម្លាតរយៈពេលកំណត់របស់ក្រសួងសុខាភិបាល ដើម្បីធានាសុវត្ថិភាពការងារ និងសុខភាពសាធារណៈ។

៤. ប្រធានអង្គភាពរដ្ឋក្រោមឱវាទរដ្ឋបាលរាជធានីភ្នំពេញ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា គណៈកម្មការផ្សារ ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ទីតាំង ម្ចាស់ផ្សារឯកជន ម្ចាស់ផ្សារម៉ាត ម្ចាស់ភោជនីយដ្ឋាន-អាហារដ្ឋាន ម្ចាស់ហាងកាហ្វេ ម្ចាស់មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ វិស័យឯកជន និងម្ចាស់ទីតាំងទាំងអស់ ក្នុងមូលដ្ឋានរាជធានីភ្នំពេញ ត្រូវពង្រឹងការត្រួតពិនិត្យសុពលភាពបណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ ឬ បណ្ណចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ឬ លិខិតបញ្ជាក់ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ មុនពេលអនុញ្ញាតឱ្យបុគ្គល ឬ អតិថិជន ចូលក្នុងអង្គភាព ឬ ទីតាំងរបស់ខ្លួន។ ក្នុងករណីពិនិត្យឃើញបុគ្គលណាមួយ ឬ អតិថិជនណាមួយ គ្មានបណ្ណចាក់វ៉ាក់សាំង ឬ មិនព្រមបង្ហាញបណ្ណចាក់វ៉ាក់សាំង ឬ ប្រើប្រាស់បណ្ណចាក់វ៉ាក់សាំងដែលមានគម្លាតរយៈពេលលើសពី **៤ ខែ** ក្រោយពេលចាក់វ៉ាក់សាំងដូសទី១ ឬ លើសពី **៦ ខែ** ក្រោយពេលចាក់វ៉ាក់សាំងដូសទី២ ដាច់ខាតមិនត្រូវអនុញ្ញាតឱ្យចូលក្នុងអង្គភាព ឬ ទីតាំងរបស់ខ្លួនឡើយ ហើយត្រូវណែនាំឱ្យពួកគេរួសរាន់ទៅចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

៥. ចំពោះបុគ្គលទាំងឡាយណាដែលសង្ស័យមានជាប់ពាក់ព័ន្ធនឹងអ្នកជំងឺកូវីដ-១៩ មេរោគបំប្លែងខ្លួនថ្មីប្រភេទអូមីក្រុង ត្រូវផ្តល់ដំណឹងជាបន្ទាន់មកអាជ្ញាធរមូលដ្ឋានដែលជិតទីតាំងស្នាក់នៅរបស់ខ្លួនបំផុត ដើម្បីក្រុមគ្រូពេទ្យជំនាញចុះយកសំណាក (PCR) និងមានវិធានការទប់ស្កាត់បានទាន់ពេលវេលា ចៀសវាងការចម្លងបន្តទៅក្រុមគ្រួសារ និងសហគមន៍ជាយថាហេតុ។ ក្នុងរយៈពេលរង់ចាំលទ្ធផល (PCR) សាមីខ្លួនត្រូវពាក់ម៉ាសជាប់ជាប្រចាំ រក្សាគម្លាតសុវត្ថិភាពសង្គម-បុគ្គល និងមិនត្រូវចាកចេញពីទីតាំងដែលខ្លួនកំពុងស្នាក់នៅ ក្នុងករណីមិនចាំបាច់។

៦. គណៈបញ្ជាការដឹកនាំការអនុវត្តច្បាប់នៅថ្នាក់រាជធានីភ្នំពេញ រដ្ឋបាលខណ្ឌទាំង១៤ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងមន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធ ត្រូវសហការចុះត្រួតពិនិត្យ និងបង្កើនការយកចិត្តទុកដាក់ក្នុងការចាត់វិធានការចាំបាច់នានា ដើម្បីពង្រឹង និងជំរុញការអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាល ជាពិសេសវិធានការ "**៣ ការពារ និង ៣ កុំ**" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។ ក្នុងករណីរកឃើញបុគ្គលណាមួយបានបំពានវិធានការនេះ ដូចជា មិនពាក់ម៉ាសនៅតាមទីសាធារណៈ **ត្រូវអនុវត្តទណ្ឌកម្មរដ្ឋបាល និងទណ្ឌកម្មច្បាប់ រួមទាំងការផ្សព្វផ្សាយជាសាធារណៈចំពោះបុគ្គលល្មើស** ស្របតាមច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដោយគ្មានការលើកលែងឡើយ។

**រដ្ឋបាលរាជធានីភ្នំពេញ** សូមបញ្ជាក់ជូនជាថ្មីម្តងទៀតថា **គោលនយោបាយជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩** របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** គឺជាយុទ្ធសាស្ត្រគន្លឹះដ៏សំខាន់ និងជាខ្សែក្រវ៉ាត់ការពារទី១ ដើម្បីប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ សំដៅការពារសុខភាព និងអាយុជីវិតរបស់ប្រជាជន រហូតសម្រេចបាននូវការបើកដំណើរការសេដ្ឋកិច្ច-សង្គមឡើងវិញលើគ្រប់វិស័យ និងបានសម្រេចបិទបញ្ចប់ "**ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១**" កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ កន្លងទៅ។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

**ដូច្នេះ** សូមបណ្តាអង្គភាពរដ្ឋ វិស័យឯកជន និងប្រជាពលរដ្ឋទាំងអស់ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ត្រូវរួមគ្នាជំរុញការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ទាំងដូសមូលដ្ឋាន និងទាំងដូសជំរុញ ព្រមទាំងពង្រឹងការអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាល ឱ្យបានម៉ឺងម៉ាត់ ដើម្បីបង្កើតនិងរក្សាឱ្យបាននូវ **"ភាពស៊ាំសហគមន៍រឹងមាំពិតប្រាកដមួយ"** ទប់ទល់នឹងជំងឺរាតត្បាតសកលកូវីដ-១៩ និងដើម្បីបញ្ចៀសការសម្រេចដាក់ចេញនូវវិធានការរដ្ឋបាលណាមួយជាយថាហេតុ។

ទទួលបានសេចក្តីណែនាំនេះ នាយករដ្ឋបាលសាលារាជធានីភ្នំពេញ ស្នងការនគរបាលរាជធានីភ្នំពេញ មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ អភិបាល នៃគណៈអភិបាលខណ្ឌទាំង១៤ ប្រធានមន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ បណ្តាអង្គភាពរដ្ឋក្រោមឱវាទរដ្ឋបាលរាជធានីភ្នំពេញ វិស័យឯកជន ប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់៕

ថ្ងៃអង្គារ ៩កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០២២
**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-គ្រប់ក្រសួង-ស្ថាប័ន
-គណៈប្រចាំការនៃ គ.ប.ក
*"ដើម្បីជូនជ្រាបជាព័ត៌មាន"*
-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
-បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
-រដ្ឋបាលខណ្ឌទាំង១៤
-គ្រប់មន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ
*"ដើម្បីមុខការ!"*
-គ្រប់ប្រព័ន្ធឃោសនា
*"ដើម្បីផ្សព្វផ្សាយ"*
-ឯកសារ-កាលប្បវត្តិ



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh